# កម្មវិធីសិក្សា វប្បធម៌ទូទៅ
# សំរាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅ RULE
# ចំនួន 45 h = 3ក្រេឌីត

## កម្មវត្ថុ និងគោលបំណង :

១ ការសិក្សាអាចអភិវឌ្ឍន៍ កោសល្យរបស់និស្សិត និង សមត្ថភាពបានយ៉ាងពេញលេញ ពិសេសនៅពេលដែលនិស្សិត បញ្ចប់ការសិក្សា និស្សិតអាច :

- មានសមត្ថភាពជំនាញក្នុងការវិភាគ និងក្នុងការដោះស្រាយបញ្ហា ហើយមានបំណិន ក្នុងការទំនាក់ទំនង ពតិមាន និងផ្តុំយោបល់ រួចអាចរៀបចំផែនការ រៀបចំសកម្មភាព និងសហការជាមួយអ្នកដទៃទៀតបាន ។

- មានគុណភាព និងភាពម្ចាស់ការ សុទិដ្ឋិនិយម និងសុឆន្ទៈនិយម ស្គាល់តម្លៃខ្លួន មោទនភាព និងការប្តូផ្តាច់ ដើម្បីភាពរុងរឿង ហើយមានតួនាទីដ៏មានសក្តានុពលភាព ជាមួយ មិត្តផងគ្នា គ្រួសារ សហគមន៍ សង្គម និងអាចជាសមាជិកកម្លាំងពលកម្ម មានចំណេះដឹង ជំនាញ តរិយាបថល្អ ផងដែរ ។

- មានសមត្ថភាពថ្លឹងថ្លែង និង មានសមត្ថភាពទទួលខុសត្រូវខ្ពស់ នៅក្នុងផ្នែក សីលធម៌ ចរិយាធម៌ សុភាវធម៌ និង យុត្តិធម៌ នៅក្នុងសង្គម ហើយអាចមានសមត្ថភាពស្វែងយល់ក្នុងជីវិត ចេះគិតគូរ ចេះសំរេចកិច្ចការក្នុងជីវិតដោយខ្លួនឯង និងចេះទទួលខុសត្រូវក្នុងទង្វើ ជីវិតខ្លួនឯង បច្ចុប្បន្ន និងទៅអនាគតជាទីសង្ឃឹមរបស់អាណាព្យាបាល និងប្រទេសជាតិ ក៏ដូចជារាជរដ្ឋាភិបាល ។

- មានទំនុកចិត្ត និងការជឿជាក់ ឆ្នៃប្រឌិត គំនិតផ្តើម ជាអ្នកប្រើប្រាស់បច្ចេកវិជ្ជាថ្មីយ៉ាងផុសផុល សស្រាក់សស្រាំ ជាពិសេស ប្រើប្រាស់បច្ចេកវិជ្ជាខាងផ្នែកពតិមាន និងទំនាក់ទំនង Intermational ហើយយល់ដឹងពីឥទ្ធិពលនៃបច្ចេកវិជ្ជាទាំងនោះជះទៅលើសង្គមយើង ។

- មានការយល់ដឹង និង ការយកចិត្តទុកដាក់ មានស្មារតីថែរក្សាបរិស្ថាន និងចំណេះដឹង ជំនាញគ្រប់គ្រាន់ ដើម្បីអភិវឌ្ឍន៍ និងទ្រទ្រង់ បរិស្ថាន សង្គមជាតិ និងអន្តរជាតិ ។

២ ការសិក្សាត្រូវមានសមធម៌ក្នុងសង្គម ដោយគ្មានលំអៀង

-លទ្ធផលជាសមិទ្ធិផលរបស់និស្សិតដែលទទួលបានពីការសិក្សា គឺធ្វើអោយនិស្សិតទាំងនោះមានសេរីភាពពេញ លេញ ដោយមិនបែង ចែក ឬប្រកាន់ពូសាសន៍ ជាតិសាសន៍ អំបូរសាសន៍ មរតិកសាសន៍ ភេទ ពណ៌សម្បុរ ភាសា វប្បធម៌ សាសនា និង ភាពបាត់បង់សមត្ថភាពពលកម្ម ហើយនិស្សិតគេចផុតពីឥទ្ធិពលផ្សេង១ ដែលកើតឡើងមកពីទីតាំងភូមិសាស្ត្រ រួមនិងសាវតា សេដ្ឋកិច្ចសង្គម ហើយនិងឥទ្ធិពលនៃការសំរេចចិត្ត ផ្សេង១ ។

- បណ្តានិស្សិតអាទិភាព សុទ្ធតែមានសិទ្ធិ និងឱកាសទទួលការអប់រំប្រកបដោយសមធម៌ ដើម្បីអោយលទ្ធិផលនៃការសិក្សារបស់ពួកគេ ឈានឡើងជាលំដាប់ ដោយបណ្តុះបណ្តាលពួកគេអោយរៀនសូត្របន្ថែម ។

- ធ្វើអោយនិស្សិតទាំងអស់យល់ ហើយទទួលស្គាល់តំលៃវប្បធម៌ខ្មែរ ដែលជាអរិយធម៌ជាតិ ផ្តល់អោយពួកគេមានចំណេះដឹងជំនាញ និង ការយល់ដឹង ប្រយោជន៍ឱ្យពួកគេចេះថែរក្សាការពារ និងចេះយកចំណេញដោយគំនិតទីផ្សារសេរី ។

| ល.រ | ខ្លឹមសារអរិយធម៌ វប្បធម៌ខ្មែរ | ចំនួនម៉ោង | ផ្សេងៗ |
|---|---|---|---|
| 1 | - និយមន័យអរិយធម៌<br>- និយមន័យវប្បធម៌<br>- និយមន័យសង្គមធម៌<br>- ការកកើតអារ្យធម៌ខ្មែរ<br>- ពូជអំបូរមនុស្សខ្មែរ<br>- ប្រភពសិល្បៈខ្មែរ | **3 h** | |
| 2 | **អក្សរសាស្ត្រខ្មែរ**<br>- អក្សរសាស្ត្រជាអ្វី ? ប្រវត្តិអក្សរសាស្ត្រ<br>- សមាសភាព ដើម្បីលាតត្រដាងអក្សរសាស្ត្រ<br>- ការបែងចែកប្រភេទអក្សរសាស្ត្រ<br>- បណ្ដាឫសគល់អក្សរសាស្ត្រ<br>- ចលនាអក្សរសាស្ត្រខ្មែរ | **6 h** | |
| 3 | **សិល្បៈ និង របាំខ្មែរ** | **12 h** | |
| 4 | **ពិធីបុណ្យ និង ប្រពៃណីយ៍ ទំនៀមទំលាប់ខ្មែរ** | **6 h** | |
| 5 | I. **ព្រហ្មញ្ញសាសនា**<br>- ការវិវត្តន៍របស់ព្រាហ្មសាសនិក<br>- គម្ពីរវេទ<br>- ព្រហ្ម័ន អាត្ម័ន និង ធម៌ន<br>- ឥទ្ធិពលទេវៈមកលើការគ្រប់គ្រងប្រទេសជាតិ និង លទ្ធិទេវរាជ<br>- មុខងារ និង លក្ខណៈសម្គាល់បែបព្រាហ្មណ៍ ក្នុងសង្គមខ្មែរ | **6 h** | |
| | II. **ពុទ្ធសាសនា និងសង្គមខ្មែរ**<br>- ពុទ្ធប្បវត្តិ<br>- គម្ពីរព្រះត្រៃបិដក<br>- ឫសគល់ពុទ្ធសាសនា<br>- សីលធម៌ពុទ្ធនិយមក្នុងសង្គមខ្មែរ | **6 h** | |
| | III. **ឥទ្ធិពលពុទ្ធសាសនា ក្នុងសង្គមខ្មែរ** | **3 h** | |

| | | | |
|---|---|---|---|
| | ‐ជីវភាពប្រជាពលរដ្ឋខ្មែរ និង វត្តអារាម<br>‐វត្តអារាម និង សង្គមខ្មែរ | | |
| 6 | **រំលឹកមេរៀនត្រៀមប្រលង** | **3 h** | |

**ឯកសារយោង**


- វប្បធម៌អរិយធម៌ ខ្មែរ- ឥណ្ឌ ភិក្ខុ ប៉ាង ខាត់ 1970
- ពុទ្ធសាសនា ២៥០០ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ភិក្ខុ វីរយ បណ្ឌិតប៉ាង ខាត់ 1957
- វប្បធម៌ ឥណ្ឌ -ខ្មែរ គង់ នឿន 1971
- អរិយធម៌ខ្មែរ ត្រឹង-ងា 1975
- វប្បធម៌អរិយធម៌ ខ្មែរ សាស្ត្រាចារ្យ លី-សុមុនី 2003


# Course Assessment

- **Attendants 10%**
- **Assignment 15%**
- **Midterm 25%**
- **Final Examine 50%**